**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សេចក្តីជូនដំណឹង

ក្រសួងមុខងារសាធារណៈ សូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់មេត្តាជ្រាបថា **ឧបាសិកា អ៊ិន សាម៉ុន** ដែលត្រូវជាម្តាយបង្កើតលោក **ហែន សារិទ្ធ** អគ្គាធិការរងនៃអគ្គាធិការដ្ឋានក្រសួងមុខងារសាធារណៈ បានទទួលមរណភាពនៅថ្ងៃសៅរ៍ ៦កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ១:៣០នាទីរំលងអធ្រាត្រ ក្នុងជន្មាយុ៧៧ឆ្នាំ ដោយជរាពាធ។

**ឯកឧត្តម រឿង រដ្ឋា** អនុរដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហ៊ុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនឹងអញ្ជើញដឹកនាំប្រតិភូចូលរួមពិធីបុណ្យគម្រប់ខួប៧ថ្ងៃរបស់ ឧបាសិកា អ៊ិន សាម៉ុន ដែលនឹងប្រារព្ធទៅនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២ នៅគេហដ្ឋាននៃសព ស្ថិតនៅភូមិម្រះព្រៅ ឃុំត្រពាំងស្តៅ ស្រុករមាសហែក ខេត្តស្វាយរៀង។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** មេត្តាជ្រាបជាព័ត៌មាន និងចូលរួមរំលែកទុក្ខ ព្រមទាំងចាប់មគ្គផលតាមសទ្ធាជ្រះថ្លារៀងៗខ្លួន។
**លោក ហែន សារិទ្ធ "HEN SARITH"** មានគណនី ABA Bank ៖ 001560140 ( ដុល្លារ )
ABA Bank ៖ 001560149 ( ខ្មែររៀល )

ថ្ងៃ ចន្ទ ៨កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២២

ក្រសួងមុខងារសាធារណៈ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សាររំលែកមរណទុក្ខ

**ជូនចំពោះ**

**លោក ហែន សារិទ្ធ អគ្គាធិការរង នៃអគ្គាធិការដ្ឋាន ព្រមទាំងក្រុមគ្រួសារ**

**ចំពោះមរណភាពរបស់ ឧបាសិកា អ៊ិន សាម៉ុន**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្តីក្តុកក្តួល និងសោកស្តាយឥតឧបមា ដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា **ឧបាសិកា អ៊ិន សាម៉ុន** ជាម្តាយបង្កើតរបស់ លោក ហែន សារិទ្ធ អគ្គាធិការរង នៃអគ្គាធិការដ្ឋានបានទទួលមរណភាព នៅថ្ងៃសៅរ៍ ៦កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី០១ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ១:៣០នាទីរំលងអធ្រាត្រ ក្នុងជន្មាយុ ៧៧ឆ្នាំ ដោយជរាពាធ។

ស្ថិតក្នុងវេលាដ៏សោកសង្រេង និងក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្តែងនូវសេចក្តីសោកស្តាយ ស្រណោះ អាឡោះអាល័យបំផុតចំពោះការបាត់បង់ **ឧបាសិកា អ៊ិន សាម៉ុន** ដែលជាម្តាយបង្កើត ម្តាយក្មេក និងជាជីដូនប្រកបដោយព្រហ្មវិហារធម៌មិនចេះរីងស្ងួត និងសង្គហធម៌ដ៏ល្អប្រពៃរបស់ក្រុមគ្រួសារ។

យើងខ្ញុំទាំងអស់គ្នា សូមចូលរួមរំលែកទុក្ខដោយសេចក្តីសោកសង្រេងបំផុតជាមួយ **លោក ព្រមទាំងក្រុមគ្រួសារ** និងសូមឧទ្ទិសបួងសួងចំពោះដួងវិញ្ញាណក្ខន្ធរបស់ **ឧបាសិកា អ៊ិន សាម៉ុន** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោក ហែន សារិទ្ធ ព្រមទាំងក្រុមគ្រួសារ** ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ៕

ថ្ងៃព្រហ ៣រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**

**រដ្ឋមន្ត្រី**

ព្រំ សុខា

ផ្លូវវិថីអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh